ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៤៥១ សហវ.ឧបក.ពដ

# ប្រកាស
# ស្តីពី
# ឆ្នាំជាប់ពន្ធ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញប្រកាសលេខ១០៩៩ សហវ.បក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់ចំណេញ
- យោងតាមការចាំបាច់នៃការងារគ្រប់គ្រងប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ

## <u>សម្រេច</u>

**ប្រការ ១.-** ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីសារពើពន្ធ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណេញរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម :

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

១. គ្រប់សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ឆ្នាំជាប់ពន្ធគឺជាឆ្នាំប្រតិទិន ដែលចាប់ផ្តើមពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ។ ចំពោះសហគ្រាសថ្មី ឆ្នាំជាប់ពន្ធដំបូង ត្រូវគិតចាប់តាំងពីថ្ងៃដែលផ្តើមធ្វើអាជីវកម្មមកទល់ នឹងថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំដែលត្រូវគិតពន្ធ។

២. សហគ្រាសនីតិបុគ្គលដែលបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានកម្មសិទ្ធលើតម្លៃភាគកម្មក្នុងដើមទុនផ្ទាល់របស់សហគ្រាសចាប់ពី ៥១ ភាគរយឡើងទៅជារបស់ក្រុមហ៊ុនមេនៅបរទេសអាចស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មី ខុសពីឆ្នាំជាប់ពន្ធ(ប្រតិទិន)ដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការទាំងឡាយខាងក្រោម ។

**ប្រការ ២.** សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដូចមានចែងក្នុងកថាខណ្ឌ ២ នៃប្រការ ១ ត្រូវស្នើសុំមកនាយកដ្ឋានពន្ធដារដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម :

១. លិខិតបញ្ជាក់ពីក្រុមហ៊ុនមេដែលនៅបរទេសអំពីការប្រើប្រាស់ឆ្នាំជាប់ពន្ធថ្មីខុសពីឆ្នាំប្រតិទិន

២. លិខិតបញ្ជាក់ពីសវនករឯករាជ្យរបស់ក្រុមហ៊ុនមេដែលនៅបរទេស អំពីការប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន

៣. ច្បាប់ចម្លងនៃលក្ខន្តិកៈក្រុមហ៊ុនរបស់សហគ្រាស ដែលអាចបញ្ជាក់បាននូវអត្តសញ្ញាណរបស់ក្រុមហ៊ុនមេនៅបរទេស ។

**ប្រការ ៣.** សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដូចមានចែងក្នុងកថាខណ្ឌ២ នៃប្រការ១ ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដោយអនុវត្តតាមការិយបរិច្ឆេទដូចខាងក្រោម :

១. ការិយបរិច្ឆេទអន្តរកាល :

ក. ចំពោះសហគ្រាសចាស់ : គឺគិតចាប់ផ្តើមពីថ្ងៃទី ០១ ខែមករា នៃឆ្នាំដែលការស្នើសុំបានធ្វើឡើងរហូតដល់ថ្ងៃមុនថ្ងៃចាប់ផ្តើមនៃឆ្នាំជាប់ពន្ធថ្មីដែលបានស្នើសុំ ។

<u>ឧទាហរណ៍</u> : នៅក្នុងឆ្នាំ២០០៧ សហគ្រាសមួយបានស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដែលចាប់ផ្តើមពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា ។ ដូចនេះការិយបរិច្ឆេទអន្តរកាលត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ ។

ខ. ចំពោះសហគ្រាសបង្កើតថ្មី : គឺគិតចាប់ផ្តើមធ្វើអាជីវកម្ម ដល់ថ្ងៃមុនថ្ងៃចាប់ផ្តើមនៃឆ្នាំជាប់ពន្ធថ្មីដែលបានស្នើសុំ ។

<u>ឧទាហរណ៍ទី១</u> : សហគ្រាសមួយត្រូវបានបង្កើតថ្មីនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧ ។ សហគ្រាសថ្មីនេះស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដែលចាប់ផ្តើមពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែមិថុនា ។ ដូចនេះ ការិយបរិច្ឆេទអន្តរកាលត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ ។

ឧទាហរណ៍ទី២: ក្នុងករណីសហគ្រាសត្រូវបានបង្កើតថ្មីនៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៧ ។ សហគ្រាសថ្មីនេះស្នើសុំអនុវត្តឆ្នាំជាប់ពន្ធថ្មីដែលចាប់ពី ថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី ៣០ ខែមិថុនា ។ ដូចនេះការិយបរិច្ឆេទអន្តរកាលត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ។

២. ការិយបរិច្ឆេទបន្ត (ឆ្នាំជាប់ពន្ធថ្មី): គឺជារយៈពេល ១២ ខែ បន្ទាប់ពីដំណាច់ការិយបរិច្ឆេទអន្តរកាល ។

ឧទាហរណ៍ : បន្តពីឧទាហរណ៍ទី២ខាងលើ ការិយបរិច្ឆេទបន្ត (ឆ្នាំជាប់ពន្ធថ្មី) ត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ។

**ប្រការ ៤.-** ទាយជ្ជទានឱ្យដល់រំលស់សម្រាប់ការិយបរិច្ឆេទអន្តរកាល ត្រូវបានគណនាតាមសមាមាត្រនៃចំនួនថ្ងៃនៃការិយបរិច្ឆេទអន្តរកាល ធៀបទៅនឹងចំនួន ៣៦៥ ថ្ងៃនៃឆ្នាំ ។

ឧទាហរណ៍ : សហគ្រាសមានការិយបរិច្ឆេទអន្តរកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ ។ ក្នុងករណីនេះចំនួនថ្ងៃគិតរំលស់មាន ១៨២ ថ្ងៃ ។ ទាយជ្ជទានឱ្យដល់រំលស់ក្នុងមួយឆ្នាំពេញស្មើនឹង ៤២.០០០.០០០ រៀល ។ ដូច្នេះ ទាយជ្ជទានឱ្យដល់រំលស់សម្រាប់ការិយបរិច្ឆេទអន្តរកាលគឺ : ៤២.០០០.០០០ x ១៨២ / ៣៦៥ = ២០.៩៤២.៤៦៦ រៀល ។

**ប្រការ ៥.-** ដូចមានចែងក្នុងមាត្រា១៧ នៃច្បាប់ស្តីពីសារពើពន្ធ ការយោងការខាតបង់សម្រាប់ការិយបរិច្ឆេទអន្តរកាល ត្រូវគិតស្មើមួយឆ្នាំ ។

**ប្រការ ៦.-** ការដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តដូចខាងក្រោម :

១. ចំពោះសហគ្រាសដែលអនុវត្តឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន : យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ។

២. ចំពោះសហគ្រាសដែលស្នើសុំប្តូរឆ្នាំជាប់ពន្ធថ្មី :

ក. ក្នុងរយៈពេល ៣ ខែ បន្ទាប់ពីដំណាច់ការិយបរិច្ឆេទអន្តរកាល

ខ. ក្នុងរយៈពេល ៣ ខែ ក្រោយដំណាច់ឆ្នាំជាប់ពន្ធថ្មី ។

**ប្រការ ៧.-** ក្នុងករណីដែលនាយកដ្ឋានពន្ធដារមានហេតុផលសមស្របថា ការស្នើសុំនិងការអនុវត្តន៍ឆ្នាំជាប់ពន្ធថ្មីមានភាពមិនប្រក្រតីដែលនាំឱ្យបាត់បង់ប្រាក់ពន្ធ នាយកដ្ឋានពន្ធដារមានសិទ្ធិបដិសេធ ឬពន្យារពេល ឬលុបចោលការប្រើប្រាស់ឆ្នាំជាប់ពន្ធថ្មី ។

**ប្រការ ៨.-** អគ្គលេខាធិការ នាយកខុទ្ទកាល័យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ ២០០៧

គាត ឈន់

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- កាលប្បវត្តិ-ឯកសារ ។